៥-ព្រះភិក្ខុ **ម៉ុក ម៉ុនសុធា** ព្រះចៅអធិការ វត្តឧត្តរាវតី

៦-ព្រះមហា **ស៊ីន ខាន** មន្ត្រីសង្ឃ វត្តសំរោងអណ្តែត

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង ធម្មការ និង សាសនា និង អភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្ត អនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u> :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

192-193

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៤៥ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ចំនួន ០៩រូប នៃមន្ទីរធម្មការ និង សាសនា រាជធានីភ្នំពេញ ដែលមាន ស្នាដៃល្អក្នុងការបំពេញភារកិច្ច លើវិស័យព្រះពុទ្ធសាសនា ដូចមានរាយនាមខាងក្រោមនេះ :-

ក.មេដាយថ្នាក់ការងារ :

១-លោក **ម៉ាន មីហ្សា**	ប្រធានការិយាល័យធម្មការ នៃ មន្ទីរធម្មការ និងសាសនា រាជធានីភ្នំពេញ
២-លោក **មាស ស៊ីថា**	អនុប្រធានការិយាល័យពុទ្ធិកសិក្សា នៃមន្ទីរធម្មការ និងសាសនា រាជធានីភ្នំពេញ
៣-លោក **ហាញ់ ចំរើន**	មន្ត្រីការិយាល័យធម្មការ នៃមន្ទីរធម្មការ និងសាសនា រាជធានីភ្នំពេញ
៤-លោក **នូ ម៉ោង**	មន្ត្រីការិយាល័យធម្មការ នៃមន្ទីរធម្មការ និងសាសនា រាជធានីភ្នំពេញ

ខ.មេដាយសំរឹទ្ធការងារ :

១-លោក **ជឹម ឡាទី**	ប្រធានការិយាល័យធម្មការ ខ័ណ្ឌដូនពេញ
២-លោក **ជ័យ យឿន**	ប្រធានការិយាល័យធម្មការ ខ័ណ្ឌទួលគោក
៣-លោក **សេង ឈួន**	ប្រធានការិយាល័យធម្មការ ខ័ណ្ឌចំការមន
៤-លោក **ស៊ឹម សារមន**	មន្ត្រីការិយាល័យធម្មការ នៃមន្ទីរធម្មការ និងសាសនា រាជធានីភ្នំពេញ
៥-លោក **នួន ឈឿន**	មន្ត្រីការិយាល័យធម្មការ នៃមន្ទីរធម្មការ និងសាសនា រាជធានីភ្នំពេញ

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង ធម្មការ និង សាសនា និង អភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្ត អនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ១៦ ខែ ៧ ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

194

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៤៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

&&&&&

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ / ០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលខេត្តកណ្តាល

សំរេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជនចំនួន ០៤ រូប ដែលបានបរិច្ចាគកម្លាំងកាយចិត្ត និង ធនធាន ជួយកសាងសមិទ្ធផលផ្សេងៗ ក្នុងវត្តស្វាយជ្រំ ឃុំស្វាយជ្រំ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោម ÷

ក-មេដាយមាសស្ថាបនាជាតិ :

-ឯកឧត្តម **ជា ចំរើន** សកលវិទ្យាធិការ នៃសកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា

ខ-មេដាយសំរិទ្ធស្ថាបនាជាតិ :

១-ឧបាសក **ម៉ូ លន់** ចាស់ព្រឹទ្ធាចារ្យ

២-ឧបាសក **អ៊ុំ ម៉ាន** ចាស់ព្រឹទ្ធាចារ្យ

៣-ឧបាសក **ស្រី គួន** ចាស់ព្រឹទ្ធាចារ្យ

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និង មាត្រា២
-រាជកិច្ច
-ឯកសារ- កាលប្បវត្តិ

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ [illegible] ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៤៤ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

&&&&&

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស /រកត /១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកណ្តាល

សំ រេ ច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា** ប្រគេនព្រះតេជគុណ ញាណនិមល **លន់ សុគន្ធា** ព្រះអនុគណ ស្រុកខ្សាច់កណ្តាល និង ជាចៅអធិការវត្តស្វាយជ្រំ ឃុំស្វាយជ្រំ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ដែលមានស្នាព្រះហស្តល្អ ក្នុងការដឹកនាំកសាងសមិទ្ធផលផ្សេងៗ ក្នុងវិស័យព្រះពុទ្ធសាសនា និង សង្គម ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៤៥ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តតាកែវ

ស ម្រេ ច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន ០២រូប ដែលបានបរិច្ចាគធនធាន ជួយកសាងសមិទ្ធផលផ្សេងៗ បំរើអោយវិស័យកសិកម្ម នៅស្រុកព្រៃកប្បាស ខេត្តតាកែវ ដូចមានរាយនាមខាងក្រោម :-

ក_មេដាយមាសស្ថាបនាជាតិ :

-ឯកឧត្តម នាយឧត្តមសេនីយ៍ **ម៉ុល សារឿន** និង លោកជំទាវ ទឹកប្រាក់ចំនួន ១០.០០០ ដុល្លារ

ខ_មេដាយសំរឹទ្ធស្ថាបនាជាតិ :

-លោក **លីម ស៊ីវគង** និង ភរិយា ទឹកប្រាក់ចំនួន ២.២០០ ដុល្លារ

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ [illegible] ឆ្នាំ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..២៤៦....អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយសហមេត្រី

&&&&&

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស /រកត /១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

សំរេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **សេនា** ជូនភារធារី និង សេនាទុតិយយោធាឥណ្ឌូនេស៊ីប្រចាំកម្ពុជា ដែលមានកិច្ចសហប្រតិបត្តិការល្អ លើវិស័យយោធារវាងកម្ពុជា និង ឥណ្ឌូនេស៊ី ដោយបានផ្តល់សំភារៈយោធបរិក្ខារ ដល់កងឯកភាពអង្គរក្ស ដូចមានរាយនាមខាងក្រោម ÷

១-Drs. **Diddy Hermawan** (Charge d' Affair a.i)

២-Colonel. **Andrie T.U Sutarno, MDS** (Indonesian Defense Attacgé)

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា១ និង មាត្រា២

-រាជកិច្ច

-ឯកសារ- កាលប្បវត្តិ

រាជធានីភ្នំពេញ , ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២៤៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

&&&&&

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ / ០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

សំរេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនលោក **ម៉ាត់ អាល់មីន** ជំនួយការសេនានុពន្ធ យោធាកម្ពុជា ប្រចាំឥណ្ឌូនេស៊ី ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ច ជូនជាតិមាតុភូមិ ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ឧសភា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៣៤៨ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយសហមេត្រី

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

ស ម្រ េ ច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **សេនា** ជូនអ្នកជំនាញការបរទេស ចំនួន ០៤រូប ដែលមានស្នាដៃល្អក្នុងការសហការជួយអភិវឌ្ឍន៍កិច្ចការនយោបាយព្រៃឈើ នៅកម្ពុជា ដូចមានរាយនាមខាងក្រោម :-

១-*Mr.William B. Magrath*	មន្ត្រីជាន់ខ្ពស់ នៃ ធនាគារពិភពលោក
២-*Mr.Hunter Weiler*	នាយកអង្គការ *Cat Action Treasury*.
៣-*Mr.Joe Walston*	នាយកអង្គការ *Wildlife Conservation Society (w.c.s)*
៤-*Dr.Roslan Bin Ismail*	នាយក នៃ *Bangi Valley Technologies Sdn Bhd*.

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រី ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ [illegible] ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

193

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: [illegible]

សេចក្ដីសំរេច

ស្ដីពី

ការចាត់តាំង រដ្ឋមន្ត្រីស្ដីទី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើតក្រសួងយុត្តិធម៌
- យោងតាមសភាពការណ៍ចាំបាច់ នៃការងារ

សំ រេ ច

ប្រការ១.-ចាត់តាំង ឯកឧត្តម **អង្គ វង្សវឌ្ឍានា** ជារដ្ឋមន្ត្រីស្ដីទី នៃក្រសួងយុត្តិធម៌ ដើម្បីអោយធានាបាននូវនិរន្តរភាពការងារ របស់ក្រសួង និងការចូលរួម ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានទៀងទាត់ ។

ប្រការ២.-ក្នុងករណី ដែលឯកឧត្តម **នាថ ស៊ីថុន** មានការកែសំរួលក្នុងការដឹកនាំការងារ អនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល និងចូលរួមរាល់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី រាជរដ្ឋាភិបាល និងពិនិត្យលើសេចក្ដីសំរេចនេះឡើងវិញ ។

ប្រការ៣.-រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តសេចក្ដីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៥ សសរ

សេចក្តីសំរេច
ស្តីពី
ការចាត់តាំងរដ្ឋមន្ត្រីស្តីទី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- យោងតាមសភាពការណ៍ចាំបាច់

សំ រេ ច

ប្រការ១.- ចាត់តាំង ឯកឧត្តម អ៊ឹម សិទ្ធី ជារដ្ឋមន្ត្រីស្តីទី នៃក្រសួងអប់រំ យុវជន និងកីឡា ដោយមូលហេតុ ឯកឧត្តម តុល ឡោះ បានទទួលមរណៈភាព ។

ប្រការ២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ [illegible] ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ២
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៣៦ ស.សរ

សេចក្ដីសម្រេច

ស្ដីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

សំរេច

ប្រការ ១ : ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្ដម **ស ខេង** ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្ដីទី នៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសសម្ដេចនាយករដ្ឋមន្ត្រី ដែលត្រូវអញ្ជើញទៅបំពេញទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ចាប់ពីថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៤ រហូតដល់ពេលសម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា អញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

ប្រការ ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាល ប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត-ក្រុង និងឯកឧត្ដម ស ខេង ត្រូវអនុវត្តសេចក្ដីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ២*
- *ឯកសារ- កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៤៧ អនក្រ

សេចក្ដីសំរេច
ស្ដីពី
ការបង្កើតក្រុមការងារសំរាប់ពិភាក្សាជាមួយតំណាងស្នងការដ្ឋានជាន់ខ្ពស់របស់សហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន នៅកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើ ច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- សេចក្ដីសំរេច លេខ ២៦ សសរ ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៤ ស្ដីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

<u>សំរេច</u>

<u>ប្រការ ១</u> : ត្រូវបានបង្កើតក្រុមការងារសំរាប់ពិភាក្សាជាមួយតំណាងស្នងការដ្ឋានជាន់ខ្ពស់របស់សហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន នៅកម្ពុជា ដែលមានសមាសភាពដូចខាងក្រោមនេះ ៖

- ឯកឧត្ដម ឡុង វិសាលោ អនុរដ្ឋលេខាធិការ ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ — ប្រធាន
- ឯកឧត្ដម ខ្មិម យិនឡេង ទីប្រឹក្សាសម្ដេចនាយករដ្ឋមន្ត្រី — អនុប្រធាន
- ឯកឧត្ដម ឧត្ដមសេនីយ៍ឯក ម៉ៅ ច័ន្ទតារា អគ្គស្នងការរងនគរបាលជាតិ ក្រសួងមហាផ្ទៃ — សមាជិក
- ឯកឧត្ដម ម៉ុល លឹម អគ្គាធិការរង និងជាប្រធានក្រុមអ្នកច្បាប់ ក្រសួងមហាផ្ទៃ — សមាជិក
- ឯកឧត្ដម គ្រាញ់ តូនី សមាជិកក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្ដីការគណៈរដ្ឋមន្ត្រី — សមាជិក

- ឧត្តមសេនីយ៍ត្រី **គៀត ចំន្ទថារិទ្ធិ** ប្រធាននាយកដ្ឋានជនបរទេស ក្រសួងមហាផ្ទៃ សមាជិក
- លោក **កែវ ទិសិដ្ឋ** អនុប្រធាននាយកដ្ឋានច្បាប់ កុងស៊ុល ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

ប្រការ ២ : ក្រុមការងារនេះមានភារកិច្ចពិនិត្យ ពិភាក្សា លើសេចក្តីព្រាងបទដ្ឋាននានា ឬបញ្ហាទាំងឡាយ ដែលពាក់ព័ន្ធនឹងជនភៀសខ្លួន ដើម្បីលើកយោបល់ដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសំរេច ។

ប្រការ ៣ : សមាជិកក្រុមការងារត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងារ ។

ប្រការ ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី និងឯកឧត្តម អស់លោក ដែលមានឈ្មោះក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ស ៤២

ចំលងជូន :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
"ដើម្បីជូនជ្រាប"
-ដូចប្រការ៤ " ដើម្បីអនុវត្ត "
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៥ សសរ

សេចក្តីសំរេច

ស្តីពីការចាត់តាំងរដ្ឋមន្ត្រីស្តីទី

&&&

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំយុវជន និងកីឡា
- បានឃើញសេចក្តីសំរេចរបស់រាជរដ្ឋាភិបាលលេខ ២៥ សសរ ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០០៤
- យោងតាមសភាពការណ៍ចាំបាច់នៃការងាររបស់រាជរដ្ឋាភិបាល

សំរេច

ប្រការ ១ : ចាត់តាំងឯកឧត្តម ម៉ុក ម៉ន ជារដ្ឋមន្ត្រីស្តីទី នៃក្រសួងអប់រំយុវជននិងកីឡា ដោយមូលហេតុឯកឧត្តម តុល ឡោះ បានទទួលមរណភាព ។

ប្រការ ២ : ចាត់ទុកជានិរាករណ៍សេចក្តីសំរេចរបស់រាជរដ្ឋាភិបាលលេខ ២៥ សសរ ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០០៤ ។

ប្រការ ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u> :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៣*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦៥ សសរ

សេចក្តីសំរេច

ស្តីពីការប្រគល់ភារកិច្ច

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦ /០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញសេចក្តីសំរេចរបស់រាជរដ្ឋាភិបាលលេខ ២៤ សសរ ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០០៤
- យោងតាមសភាពការណ៍ចាំបាច់នៃការងាររបស់រាជរដ្ឋាភិបាល

សំ រេ ច

ប្រការ ១ : ចាត់ទុកជានិរាករណ៍សេចក្តីសំរេចរបស់រាជរដ្ឋាភិបាលលេខ ២៤ សសរ ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០០៤ ។

ប្រការ ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
លេខ :......១២៥.......បទ.ប្រក

ភ្នំពេញ , ថ្ងៃទី ១២ ខែ ០៥ ឆ្នាំ ២០០៤

ប្រកាស

ស្តីពីការ បង្កើតគណៈកម្មការរៀបចំគំរោងសំរាប់ការអភិវឌ្ឍន៍ លើវិស័យទូរគមនាគមន៍

រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

-បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការបង្កើតក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
-បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន
-បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ/បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
-បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការកែសំរួល និងបំពេញបន្ថែមនាយកដ្ឋានមួយចំនួន នៃក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
-បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ / បក ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០៣ ស្តីពីការតម្លើងនាយកដ្ឋានរដ្ឋបាល និងបណ្តុះបណ្តាល ទៅជាអគ្គនាយកដ្ឋានរដ្ឋបាល នៃក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
-យោងតាមការងារចាំបាច់របស់ក្រសួង

សំរេច

ប្រការ១ : ត្រូវបានបង្កើតគណៈកម្មការមួយ របស់ក្រសួង ដើម្បីរៀបចំ គំរោងសំរាប់ការអភិវឌ្ឍន៍ លើវិស័យទូរគមនាគមន៍ ដែលមានសមាសភាពដូចខាងក្រោម ÷

១-ឯកឧត្តម	ផាន់ គិន	រដ្ឋលេខាធិការ	ប្រធាន
២-ឯកឧត្តម	ឡា ណារ៉េត	អនុរដ្ឋលេខាធិការ	អនុប្រធាន
៣-ឯកឧត្តម	ភួយ	គីមសាំ អនុរដ្ឋលេខាធិការ	សមាជិក

កាច់ជ្រុងវិថីលេខ ១៣ និង ១០២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ
ទូរស័ព្ទ: (៨៥៥) ២៣-៧២៤៨១០, ៤២៦៥១០
ទូរសារ: (៨៥៥) ២៣-[illegible]

៤-ឯកឧត្តម	ឡុង	វ៉ាន់ហាន	អនុរដ្ឋលេខាធិការ	សមាជិក
៥-ឯកឧត្តម	គុយ	ពុំ	អគ្គនាយករដ្ឋបាល	សមាជិក
៦-ឯកឧត្តម	នូច	ហេង	អគ្គនាយកប្រៃសណីយ៍ និងទូរគមនាគមន៍	សមាជិក
៧-លោក	ញាណា	ស្រស់	អគ្គនាយករង រដ្ឋបាល	សមាជិក
៨-លោក	កែវ	ទុន្សឿន	អគ្គនាយករង រដ្ឋបាល	សមាជិក
៩-លោក	មាស	ប៉ូ	អគ្គនាយករង ប្រៃសណីយ៍ និងទូរគមនាគមន៍	សមាជិក
១០-កញ្ញា	ឡោ	ម៉ាយគៀង	អគ្គនាយករង ប្រៃសណីយ៍ និងទូរគមនាគមន៍	សមាជិក
១១-លោក	ព្រុំ	សុន្ធារ	អគ្គនាយករង ប្រៃសណីយ៍ និងទូរគមនាគមន៍	សមាជិក
១២-លោក	ឡាយ	ម៉ារីទូ	អគ្គនាយករង រដ្ឋបាល	សមាជិក
១៣-លោក	លី	សំអាន	ប្រធាននាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ	សមាជិក
១៤-លោក	ឆេព	ម៉ុន្ធា	ប្រធាននាយកដ្ឋានផែនការ-ហិរញ្ញវត្ថុ	សមាជិក
១៥-លោក	ស៊ា	ណារ៉េត	ប្រធាននាយកដ្ឋានរលកអាកាសវិទ្យុ និងអាជ្ញាប័ណ្ណ	សមាជិក
១៦-លោក	គិម	ទីក្រា	អនុប្រធាននាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ	សមាជិក
១៧-លោក	ម៉ុច	ចរិយា	អនុប្រធាននយោបាយទូរគមនាគមន៍និយ័ត និងទំនាក់ទំនងអន្តរជាតិ	សមាជិក
១៨-លោក	ឡេង	បុគន្ធ	ប្រធានការិយាល័យបូកសរុប និងស្ថិតិ	ជំនួយការ
១៩-កញ្ញា	ឌុន	ណារិទ្ធិ	ប្រធានការិយាល័យផែនការ	ជំនួយការ
២០-លោក	គុល	ញ៉ាក់	អនុប្រធានមជ្ឈមណ្ឌលបញ្ជូនស៊ីញ៉ាល់	ជំនួយការ

ប្រការ២ : គណៈកម្មការនេះ មានភារកិច្ច ដូចតទៅ ÷

២.១- ជាជំនួយការជូនដល់ ***ឯកឧត្តមរដ្ឋមន្ត្រី*** ក្នុងការរៀបចំគំរោងលំអិត ស្តីពីការ អភិវឌ្ឍន៍ វិស័យទូរគមនាគមន៍ ក្នុងកិរតកំណត់ទឹកប្រាក់ ដែលស្ថិតក្នុងក្របខ័ណ្ឌ ជាប្រាក់កម្ចី និង ជំនួយពីបរទេស ។

២.២- សហការជាមួយគ្រប់អង្គភាព និង អន្តរក្រសួងនានា ដែលមានការពាក់ព័ន្ធ មានជាអាទិ៍ : ការងារបច្ចេកទេសជំនាញ , ការវិភាគគំរោងសេដ្ឋកិច្ច.......... ។ល ។ ក្នុងការរៀបចំបណ្តាគំរោងអភិវឌ្ឍន៍ទាំងនោះ ។

២.៣- ចូលរួមសំរបសំរួល និង ពិភាក្សាជាមួយម្ចាស់អំណោយ ក្នុងករណីមានសំណូមពរ ដើម្បីទទួលបានប្រសិទ្ធភាពនិងលទ្ធផលល្អ ក្នុងកិច្ចដំណើរការរៀបចំបណ្តាគំរោងខាងលើនេះ ។

២.៤- ពេលបញ្ចប់ការងាររបស់ខ្លួន គណៈកម្មការនេះ ត្រូវរៀបចំធ្វើការបូកសរុបពីលទ្ធផលការងារ រៀបចំបណ្តា គំរោងអភិវឌ្ឍន៍ទាំងអស់នោះ និងលើកជាយោបល់ ជូន ***ឯកឧត្តមរដ្ឋមន្ត្រី*** ដើម្បីសុំការពិនិត្យ សំរេច

២.៥- គណៈកម្មការត្រូវចូលរួមប្រជុំ តាមការអញ្ជើញ របស់ ***ឯកឧត្តមប្រធាន*** ។

ប្រការ៣ : រាល់ប្រកាសទាំងឡាយណាដែលផ្ទុយពីខ្លឹមសារ នៃ ប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ៤ : អគ្គនាយកដ្ឋានរដ្ឋបាល-អគ្គនាយកដ្ឋាន ប.ទ-នាយកដ្ឋានប្រៃសណីយ៍-នាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ-នាយកដ្ឋានទូរគមនាគមន៍ ក្នុងប្រទេស និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តន៏ តាមខ្លឹមសារ នៃប្រកាសនេះ ។

ប្រការ៥ : ប្រកាសនេះមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ស្ទុស . ឃុន

កន្លែងទទួល

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

"ដើម្បីជូនជ្រាប"

-ដូចប្រការ ៤ "ដើម្បីអនុវត្តន៏"

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង អប់រំ យុវជន និង កីឡា
លេខ : ៥៥៥ សអយក .ប្រក

ប្រកាស
ស្តីពី
តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់
សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

****

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១១៩៨ .៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញ ព្រះរាជក្រមលេខ នស.រកម.០១៩៦-០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញ អនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញ អនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស

-បានឃើញ អនុក្រឹត្យលេខ ៥៦ អនក្រ.ប្រក ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៣ ស្តីពីការប្រែក្លាយមហាវិទ្យាល័យនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ទៅជាសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

សំរេច

ប្រការ ១ : សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច អក្សរកាត់ **ស.ភ.ន.វ.ស** មានតួនាទីជាមជ្ឈមណ្ឌលបណ្តុះបណ្តាល និង ស្រាវជ្រាវវិប្បធម៌ វិទ្យាសាស្ត្របច្ចេកទេស ដោយផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្តក្នុងជីវភាពសង្គម ។

ប្រការ ២ : សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ចមានភារកិច្ចដូចតទៅ ÷

-បណ្តុះបណ្តាលធនធានមនុស្សថ្នាក់មធ្យម និងថ្នាក់ឧត្តមសម្រាប់ផ្នែកច្បាប់ ផ្នែកសេដ្ឋកិច្ច ផ្នែកគណនេយ្យ ផ្នែកហិរញ្ញវត្ថុ-ធនាគារ និងផ្នែករដ្ឋបាលសាធារណៈតាមស្តង់ដាជាតិ និងអន្តរជាតិនិងធ្វើវិក្រឹតការអ្នកទាំងនោះដោយបង្កើន ទាំងបរិមាណ និងគុណភាព ស្របតាមតម្រូវទីផ្សារ ពលកម្ម និងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមទាំងក្នុងប្រទេស និងក្រៅប្រទេស : បណ្តុះបណ្តាលតាមប្រព័ន្ធសាកលវិទ្យាល័យ តាមរយៈការអប់រំ ការបង្រៀន ការរៀន ព្រមទាំងការបណ្តុះបណ្តាលបន្ត ដែលផ្តល់ឯកទេសជំនាញ ប្រកបដោយគុណភាព ការរៀបចំសិក្ខាសាលា និងសន្និសីទផ្សេងៗ ។ល។

-បង្កើនសមត្ថភាព ជំនាញដល់គ្រូបង្រៀន សាស្ត្រាចារ្យ និង មន្ត្រីរាជការ របស់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ។

-រៀបចំកម្មវិធីសិក្សាដោយមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និង កីឡា ។ ចំពោះកម្មវិធីសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋានត្រូវមានការទទួលស្គាល់បន្ថែមពីគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំ នៃកម្ពុជា (សេចក្តីសំរេចលេខ ០២ / ០៤ គ.ទ.ក.ស.ស.រ ចុះថ្ងៃទី ២២ ខែ មិនា ឆ្នាំ ២០០៤ ស្តីពីលក្ខខណ្ឌសំរាប់ចេញវិញ្ញាបនប័ត្រថ្នាក់ឆ្នាំសិក្សាមូលដ្ឋាននៅតាមគ្រឹះស្ថានឧត្តមសិក្សា) ។

-ផ្តល់ និងរួមផ្តល់ ជាមួយគ្រឹះស្ថានបណ្តុះបណ្តាលដទៃទៀត នូវសញ្ញាប័ត្រកំរិតជាតិ ។

-សិក្សាស្រាវជ្រាវ និងអភិវឌ្ឍកម្មវិធីសិក្សា វិធីសាស្ត្របង្រៀន ចងក្រងឯកសារជាភាសាខ្មែរ និងបរទេសសំរាប់ជាមូលដ្ឋាន នៃការស្រាវជ្រាវ ការរៀន ការបង្រៀន និងសំរាប់ផ្សព្វផ្សាយទូទៅ ។

-រៀបចំ និងដំណើរការការងារ ជ្រើសរើសនិស្សិតឱ្យចូលរៀន ការប្រឡងចេញ និងការវាយតម្លៃលទ្ធផលសិក្សាឱ្យបានត្រឹមត្រូវតាមគោលការណ៍ និងប្រកបដោយតម្លាភាព ។

-កសាងផែនការយុទ្ធសាស្ត្រសំរាប់អភិវឌ្ឍន៍ **ស.ភ.ន.វ.ស** ។

-គ្រប់គ្រងមន្ត្រីរាជការ កម្មករ សាស្ត្រាចារ្យ និស្សិត និងទ្រព្យសម្បត្តិរបស់ **ស.ភ.ន.វ.ស** ។

-ធ្វើសហប្រតិបត្តិការ ជាមួយអង្គការជាតិ អន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល និងស្ថាប័ននានា ក្នុងគោលបំណងធ្វើឱ្យកាន់តែល្អប្រសើរ នូវការសិក្សា ស្រាវជ្រាវ វប្បធម៌ វិទ្យាសាស្ត្រ និងបច្ចេកទេសទំនើប ។

ប្រការ ៣ : សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច មានរចនាសម្ព័ន្ធដូចតទៅ ÷

-មានសាកលវិទ្យាធិការមួយរូប ជាអ្នកដឹកនាំនិងគ្រប់គ្រង ព្រមទាំងសាកលវិទ្យាធិការរងចំនួនមួយរូប ឬច្រើនរូបជាជំនួយការតាមការចាំបាច់ ។

-មានមហាវិទ្យាល័យចំនួន ៤ និងថ្នាក់ក្រោយបរិញ្ញាប័ត្រមួយដែលមានកំរិតស្មើមហាវិទ្យាល័យ ÷

១-មហាវិទ្យាល័យ នីតិសាស្ត្រ មានដេប៉ាតឺម៉ង់ពីរគឺ : ដេប៉ាតឺម៉ង់ នីតិសាធារណៈ និងដេប៉ាតឺម៉ង់នីតិឯកជន

២-មហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ច និង គ្រប់គ្រង មានដេប៉ាតឺម៉ង់ពីរគឺ : ដេប៉ាតឺម៉ង់សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ហើយនិងដេប៉ាតឺម៉ង់គណនេយ្យ និង គ្រប់គ្រង

៣-មហាវិទ្យាល័យ សេដ្ឋកិច្ចពតិមានវិទ្យា

៤-មហាវិទ្យាល័យរដ្ឋបាលសាធារណៈ

៥-ថ្នាក់ក្រោយបរិញ្ញាប័ត្រ

-មានដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋានមួយដែលមានឋានៈស្មើការិយាល័យ

-មានលេខាធិការដ្ឋានមួយឋានៈស្មើការិយាល័យជាជំនួយការអោយសាកលវិទ្យាធិការ និងការិយាល័យចំនួន៥គឺ:

១-ការិយាល័យរដ្ឋបាល

២-ការិយាល័យសិក្សា

៣-ការិយាល័យស្រាវជ្រាវ

៤ការិយាល័យទំនាក់ទំនងអន្តរជាតិ

៥-ការិយាល័យគណនេយ្យ

ប្រការ ៤ : អគ្គនាយកនៃអគ្គនាយកដ្ឋានឧត្តមសិក្សាបច្ចេកទេស និង វិជ្ជាជីវៈ អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ ប្រធាននាយកដ្ឋានពាក់ព័ន្ធ និង សាកលវិទ្យាធិការនៃសាកលវិទ្យាល័យនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច មានភារកិច្ចអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ . ថ្ងៃទី ១៤ ខែឧសភា ឆ្នាំ ២០០៤

រដ្ឋមន្ត្រីស្តីទី

<u>**កន្លែងទទួល**</u> :

-ទីស្តីការគណៈរដ្ឋមន្ត្រី

-គ្រប់គ្រឹះស្ថានឧត្តមសិក្សា

<u>"ដើម្បីជ្រាបជាពត៌មាន"</u>

-ដូចក្នុងប្រកាស ៤

-កាលប្បវត្តិ-ឯកសារៈនា.បុគ្គលិក